ព្រះរាជាណាចក្រកម្ពុជា

ជាតិ-សាសនា-ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្រ្ត
# ប្រព័ន្ធព័ត៌មានសុខាភិបាល
# ២០០៨-២០១៥

សុខភាពល្អ
ប្រសើរ

ការសំរេចចិត្ត
ល្អប្រសើរ

ព័ត៌មានល្អ
ប្រសើរ

នាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល

សីហា ២០០៨

# អារម្ភកថា ១

ស្ថិតិសុខាភិបាលមានគុណភាពល្អគឺជាធនធានដ៏សំខាន់បំផុត សំរាប់ធ្វើការសំរេចចិត្តបានត្រឹមត្រូវដោយផ្អែកទៅលើភ័ស្តុតាង ការធ្វើផែនការបានល្អប្រសើរ ការត្រួតពិនិត្យតាមដាន និងការវាយតំលៃដែលអាចធ្វើឱ្យប្រជាជនមានសុខភាពល្អ។ ចាប់តាំងពីមានកំណែទំរង់នៃប្រព័ន្ធសុខាភិបាលនៅឆ្នាំ ១៩៩៥ ក្រសួងសុខាភិបាលបានបញ្ជាក់ច្បាស់ថាប្រព័ន្ធព័ត៌មានសុខាភិបាលគឺជាឧបករណ៏ដ៏សំខាន់ សំរាប់ឱ្យអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកកំណត់ ការងារជាអាទិភាព ហើយនិង ធ្វើការបែងចែកធនធាន។ ហេតុដូច្នេះហើយ ការវិនិយោគដោយទៀងទាត់ និងកើនឡើងទៅលើប្រព័ន្ធព័ត៌មានសុខាភិបាល គឺជាតំរូវការដ៏ចំាបាច់បំផុតចំពោះ ប្រទេសកម្ពុជាដែល មានការកើនឡើងនៃការទាមទារនូវព័ត៌មានសុខាភិបាលដែលមានគុណភាពល្អ។ ដោយទទួលស្គាល់នូវបញ្ហានេះហើយ ទើបគំនិតផ្តួចផ្តើមមួយចំនួននៅលើសកលលោក ដូចជាបណ្តាញរង្វាស់សុខភាពបាននិងកំពុងធ្វើដំណើការ ដើម្បីឈ្ពោះទៅពង្រឹងប្រព័ន្ធ ព័ត៌មានសុខាភិបាលរបស់បណ្តាប្រទេសនានា ជាពិសេសប្រទេសដែលកំពុងអភិវឌ្ឍន៏។

យើងសូមបង្ហាញជូននូវផែនការយុទ្ធសាស្ត្រនៃប្រព័ន្ធព័ត៌មានសុខាភិបាលលើកដំបូង ដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាដែលឆ្លុះបញ្ចាំងពីការខំប្រឹងប្រែងយ៉ាងខ្លាំង និង កិច្ចសហការដ៏រឹងមាំនៅក្នុងចំណោមស្ថាប័នសុខាភិបាលដែលពាក់ព័ន្ធ (នាយកដ្ឋានសុខាភិបាល និង កម្មវិធីជាតិ មន្ទីរសុខាភិបាលខេត្ត) ហើយនិងអ្នកផលិតទិន្នន័យដែលទាក់ទងទៅនិងសុខភាព ជាពិសេសវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអគ្គនាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ។ ឯកសារដែលបានផលិតឡើងរួមគ្នានេះផ្តល់នូវលក្ខណៈទូទៅនៃទស្សនៈវិស័យគោលបំណង និង យុទ្ធសាស្ត្រនានានៃប្រព័ន្ធព័ត៌មានសុខាភិបាល ឆ្លើយតបទៅនិងលទ្ធផល និងកង្វះខាតនៃសមាសភាគទាំងប្រាំមួយរបស់ក្របខ័ណ្ឌនៃបណ្តាញរង្វាស់សុខភាព ដែលបានវាយតំលៃកាលពីខែតុលាឆ្នាំ ២០០៦ កន្លងទៅ ដោយរាប់បញ្ចូលទាំងការសង្ឃឹមជឿជាក់របស់ប្រទេសនូវកំណែទំរង់ និងការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធព័ត៌មានសុខាភិបាល។ ផែនការយុទ្ធសាស្ត្រនេះឆ្លុះបញ្ចាំងពីការងារចំពោះមុខនានា អានុសាសន៏ គោលនយោបាយទូលាយ ការត្រៀងគរធនធាន និងគូសបញ្ជាក់ថាតើប្រព័ន្ធព័ត៌មានសុខាភិបាលអាចដំណើរការ ទៅយ៉ាងដូចម្តេចនាពេលអនាគត។

ខ្ញុំជឿជាក់ថាផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាលនេះ និងត្រូវបានប្រើប្រាស់ដោយស្ថាប័នជាតិទាំងឡាយ ដែលពាក់ព័ន្ធជាមួយផ្នែកសុខាភិបាល ហើយនិងដៃគូអភិវឌ្ឍន៏សុខាភិបាល ជាមគ្គុទ្ទេសណែនាំសំរាប់សកម្មភាពទាំងឡាយ និង ការវិនិយោគរបស់ពួកគេនៅក្នុងការត្រួតពិនិត្យតាមដាន និង ការវាយតំលៃសមិទ្ធផលវិស័យសុខាភិបាល។

ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីនៃការិយាល័យព័ត៌មានសុខាភិបាល នៃនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាលដែលបានដឹកនាំក្នុងការអភិវឌ្ឍន៏នូវផែនការយុទ្ធសាស្ត្រនេះ ក៏ដូចជាការខំប្រឹងប្រែងយ៉ាងខ្លាំងក្លា និងការចូលរួមចំណែករបស់សមាជិកនានានៃក្រុមការងារប្រព័ន្ធព័ត៌មានសុខាភិបាល។

ខ្ញុំក៏សូមសំដែងនូវការកោតសរសើរផងដែរចំពោះការគំាទ្រផ្នែកបច្ចេកទេស និង ថវិកាដែលបានផ្តល់ឱ្យដោយបណ្តាញរង្វាស់សុខភាព ហើយនិងការផ្តល់ជំនួយបច្ចេកទេសដោយអង្គការសុខភាពពិភពលោកនៃតំបន់ប៉ាស៊ីហ្វិកខាងលិច។

ថ្ងៃទី ៨ ខែ សីហាឆ្នាំ ២០០៨

សាស្ត្រាចារ្យ ឱ្យេង ហួត

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ ២

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណចំពោះការចូលរួមយ៉ាងសកម្មរបស់មន្ត្រីជាច្រើន ដែលបានអភិវឌ្ឍផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល ២០០៨-២០១៥ ប្រសិនបើគ្មានការខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តពីមន្ត្រីទាំងនេះទេ នោះផែនការយុទ្ធសាស្ត្រនេះនឹងមិនអាចកើតមានឡើយ។ ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណជាពិសេសដល់ ក្រុមការងារប្រព័ន្ធព័ត៌មានសុខាភិបាលរួមមាន លោកវេជ្ជ. ឡូ វាសនាគីរី ប្រធានក្រុមការងារ និង ជាប្រធាននាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល (ន.ផ.ព.ស) នៃក្រសួងសុខាភិបាល លោកវេជ្ជ. សៅ សុវណ្ណរតនៈ អនុប្រធាននាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល លោកស្រីវេជ្ជ. សុខ កញ្ញា អនុប្រធាន ន.ផ.ព.ស លោកសាស្ត្រាចារ្យ គុំ កាណាល់ ប្រធានមជ្ឈមណ្ឌលជាតិគាំពារ មាតានិងទារក លោកវេជ្ជ. ម៉ៅ តាន់ អ៊ាង ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគ របេង លោកវេជ្ជ. លី សុវ៉ាន់ និង លោកវេជ្ជ ហ៊ុង វ័ត្ថមុនី អនុប្រធាននាយកដ្ឋានប្រយុទ្ធនិងជំងឺឆ្លង លោកវេជ្ជ. នង សៅ គ្រី អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់ លោកស្រី យុត ថាវ៉ារី អនុប្រធាននាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុ លោកបណ្ឌិត សាផុន វឌ្ឍនៈ អនុប្រធាន វិទ្យាស្ថានជាតិសុខភាពសាធារណៈ លោកវេជ្ជ. លី ពេញស៊ុន អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ កាមរោគនិង សើរស្បែក លោកស្រី វេជ្ជ. ឃួន អេងមុនី អនុប្រធាននាយកដ្ឋានការពារសុខភាព លោកវេជ្ជ. សុខ ស្រ៊ុន អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ លោកវេជ្ជ. ទៀង ស៊ីវណ្ណា អនុប្រធានការិយាល័យបច្ចេកទេសនៃ មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង លោកស្រីវេជ្ជ. ខោល ខេមរ៉ាវី ប្រធានការិយាល័យព័ត៌មានសុខាភិបាល លោកវេជ្ជ. យក់ តារារិទ្ធ មន្ត្រីនៃ ការិយាល័យព័ត៌មានសុខាភិបាល លោក ហោ ដារិទ្ធ ប្រធាននាយកដ្ឋានជំរឿន និង អង្កេតនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ លោក ផន ចិន្តា មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ លោក យឹម សំអុល ប្រធានការិយាល័យរដ្ឋបាលទូទៅ នៃនាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ លោកវេជ្ជ. ប៉ូល វីលលីន ទីប្រឹក្សាអភិវឌ្ឍប្រព័ន្ធសុខាភិបាលនៃអង្គការសុខភាពពិភពលោក លោកវេជ្ជ. សៀង ណម តំណាងអង្គការយូនីសេហ្វ លោកវេជ្ជ. ឆោម វ៉ាដា តំណាងអង្គការហ្ស៊ីធីសិត លោកស្រីវេជ្ជ. សំ សុជា តំណាងអង្គការយូអិនអេហ្វភីអេ លោកវេជ្ជ. ស៊ីន សុមុនី តំណាងអង្គការមេឌីខាម លោកស្រីវេជ្ជ. លីម ណារី តំណាងអង្គការវ៉ាឆា លោកវេជ្ជ. ប៉េង វ៉ានី តំណាងអង្គការ យូអរស៊ី និង លោកវេជ្ជ. វិជ័យ វ៉ាវ ជំនាញការផ្នែកការត្រួតពិនិត្យតាមដាន និង វាយតំលៃ នៃគំរោងទ្រទ្រង់ វិស័យសុខាភិបាល។

ក្រសួងសុខាភិបាលក៏សូមថ្លែងអំណរគុណផងដែរចំពោះមន្ត្រីសុខាភិបាលខេត្ត-ក្រុង ដែលបានចូលរួម ចំណែកក្នុងការអភិវឌ្ឍន៍នូវផែនការយុទ្ធសាស្ត្រនេះឡើង។

ក្រសួងសុខាភិបាលក៏សូមថ្លែងអំណរគុណជាពិសេសផងដែរដល់លោកវេជ្ជ. ប្រ៊ុយណូ ព្យ៉ូទី និង លោកវេជ្ជ. ស្ទីវ សាភារី ទីប្រឹក្សាបច្ចេកទេសរបស់បណ្តាញរង្វាស់សុខភាព ដែលបានផ្តល់ជំនួយបច្ចេកទេស និង សំរបសំរួលការធ្វើសិក្ខាសាលា។ ក្រសួងសុខាភិបាលសូមសំដែងការកោតសរសើរដល់ លោកវេជ្ជ. យ៉ុក ឈីង ឆុង អតីត ទីប្រឹក្សាប្រព័ន្ធព័ត៌មានសុខាភិបាល នៃអង្គការសុខភាពពិភពលោកនៅតំបន់ប៉ាស៊ីហ្វិកខាងលិច ដែលបានផ្តល់ ការណែនាំ និង ជួយក្នុងការរៀបចំធ្វើផែនការយុទ្ធសាស្ត្រព័ត៌មានសុខាភិបាល។

# មាតិកា


| | |
|---|---|
| ១-អារម្ភកថា | ១ |
| ២-សេចក្តីថ្លែងអំណរគុណ | ២ |
| ៣-អត្ថបទសង្ខេប | ៧ |
| ៤-សេចក្តីផ្តើម | ១០ |
| ៥-សារបាន | ១២ |
| ក-ប្រវត្តិសង្ខេបនៃប្រព័ន្ធព័ត៌មានសុខាភិបាល | |
| ខ-បរិបទគោលនយោបាយ | ១៣ |
| ▪ គោលនយោបាយរដ្ឋាភិបាល និង ផែនការនានា | |
| ▪ ផែនការយុទ្ធសាស្ត្រសុខាភិបាល | ១៤ |
| គ-លទ្ធផលនៃការវាយតំលៃប្រព័ន្ធព័ត៌មានសុខាភិបាល | |
| ៦-សន្និទានភាគ | ២២ |
| ក-តំរូវការព័ត៌មានសុខាភិបាល | |
| ខ-ស្ថាប័ននានា និង ដៃគូប្រព័ន្ធព័ត៌មានសុខាភិបាល | |
| គ-គុណភាពទិន្នន័យ (PARIS21) | |
| ឃ-បញ្ហាសុខភាពអាទិភាព និង សេវាសុខាភិបាលសារវ័ន្ត | |
| ង- អំាងឌីកាទ័រសុខភាពសំខាន់ៗ | |
| ច- ការគ្រប់គ្រងផែនការ | |
| ៧-ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ | ២៤ |
| ក-ទស្សនះវិស័យ និងគោលបំណង | |
| ខ- យុទ្ធសាស្ត្រ | |
| ៨-ផែនការអភិវឌ្ឍន៏យុទ្ធសាស្ត្រ | ៣២ |
| ក-ការបរិយាយសង្ខេបនៃផែនការអនុវត្តន៏យុទ្ធសាស្ត្រ និង ការទទួលខុសត្រូវ | |
| ខ- សកម្មភាព: ពេលវេលា លទ្ធផល ការទទួលខុសត្រូវ និង តំរូវការថវិកា | |
| ៩-ការត្រួតពិនិត្យតាមដាន និង វាយតំលៃ | ៥៥ |
| ១០-លក្ខ័ណដើម្បីជោគជ័យ | ៧៤ |
| ១១-ឧបសម្ព័ន្ធ | ៧៥ |

# ពាក្យបំព្រួញ

ក្រ.ផ: ក្រសួងផែនការ

ក្រ.ម.ផ: ក្រសួងមហាផ្ទៃ

ក្រ.ឆ.រ: ក្រុមឆ្លើយតបរហ័ស

ន.ផ.ព: នាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល

ន.ម: នាយកដ្ឋានមន្ទីរពេទ្យ

ន.ប្រ.ឆ: នាយកដ្ឋានប្រយុទ្ធនិងជំងឺឆ្លង

ន.ក.ស: នាយកដ្ឋានការពារសុខភាព

ន.ឱ.ច: នាយកដ្ឋានឱសថ និង ចំណីអាហារ

ន.ធ.ម: នាយកដ្ឋានធនធានមនុស្ស

ន.ថ.ហ: នាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុ

ន.រ.ទ: នាយកដ្ឋានរដ្ឋបាលទូទៅ

ប.ប: បណ្តុះបណ្តាល

ប.រ.ស: បណ្តាញរង្វាស់សុខភាព

ប្រ.ព.ស: ប្រព័ន្ធព័ត៌មានសុខាភិបាល

ផ.យ.ប្រ.ព.ស: ផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល

ម.ស.ខ: មន្ទីរសុខាភិបាលខេត្ត

ម.ប: មន្ទីរពេទ្យបង្អែក

វ.ស: វិទ្យាស្ថានជាតិស្ថិតិ

វ.ស.ស: វិទ្យាស្ថានជាតិសុខភាពសាធារណៈ

អ.ប្រ.ស: អង្កេតប្រជាសាស្ត្រ និងសុខភាព

CENAT: National Center for Tuberculosis and Leprosy Control
CDHS: Cambodia Demographic and Health Survey
CIPS: Cambodia Inter-censal Population Survey
CSES: Cambodia Socio-economic survey
CMDG: Cambodia Millennium Development Goals
CNM: National Center for Malaria
DPHI: Department of Planning and Health Information
EPI: Expanded Program on Immunization
GMS: Greater Mekong Sub-Regions
MCH: Maternal and Child Health
NCHADS: National Center for HIV/AIDS, Dermatology and Sexually Transmitted Diseases
NHIS: National Health Information System
HMIS: Health Management Information System
NPRS: National Poverty Reduction Strategy
NSDP: National Strategic Development Plan 2006-2010
OPD: Out-patient department
OD: Operational district
PES: Post Enumeration Survey
RACHA/USAID: Reproductive and Child Health Alliance
URC/USAID: University Research Co.,LLC

# អត្ថបទសង្ខេប ៣

ផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល ២០០៨-២០១៥ (ផ.យ.ប្រ.ព.ស) គឺជាយុទ្ធសាស្ត្រលើកដំបូងដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើការវាយតំលៃគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធព័ត៌មានសុខាភិបាលបច្ចុប្បន្ន ហើយនិងតំរូវការនានាពីអ្នកប្រើប្រាស់ជាច្រើន។ ផែនការយុទ្ធសាស្ត្រនេះ គឺផលិតផលរួមគ្នាដែលបង្កើតដោយក្រុមការងារនៃប្រព័ន្ធព័ត៌មានសុខាភិបាលដែលរួមមានស្ថាប័នសុខាភិបាលដែលពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិនៃ ក្រសួងផែនការ និង អគ្គនាយកដ្ឋានរដ្ឋបាលទូទៅ នៃក្រសួងមហាផ្ទៃ ក៏ដូចតំណាងនៃដៃគូអភិវឌ្ឍន៍សុខាភិបាលនានា។ ការពិភាក្សាអំពីយុទ្ធសាស្ត្របានចាប់ផ្តើមឡើងតាំងពីពាក់កណ្តាលឆ្នាំចុងក្រោយនៃឆ្នាំ ២០០៦ និងបញ្ចប់នៅក្នុងខែធ្នូ ២០០៧។ ថវិកា និង ជំនួយបច្ចេកទេសដើម្បីបង្កើតផែនការយុទ្ធសាស្ត្រនេះ រួមទាំងការវាយតំលៃប្រព័ន្ធព័ត៌មានសុខាភិបាលត្រូវបាន ផ្តល់ឱ្យដោយបណ្តាញរង្វាស់សុខភាព និង អង្គការសុខភាពពិភពលោក។

ទស្សនៈវិស័យនៃប្រព័ន្ធព័ត៌មានសុខាភិបាលគឺ "ត្រូវមានព័ត៌មានសុខាភិបាល និងព័ត៌មានដែលទាក់ទងទៅនិងសុខាភិបាល ដែលមានលក្ខណៈពាក់ព័ន្ធ ទាន់ពេលវេលា និងមានគុណភាពខ្ពស់ សំរាប់ធ្វើគោលនយោបាយ ធ្វើការសំរេចចិត្តដោយផ្អែកទៅលើភស្តុតាងជាក់ស្តែង ការអនុវត្តន៏កម្មវិធី និង ការត្រួតពិនិត្យតាមដាន និងការវាយតំលៃដើម្បីចូលរួមចំណែកធ្វើឱ្យសុខភាពប្រជាជនបានល្អប្រសើរឡើង"។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះមានគោលបំណង ៥ ដែលអាចធ្វើឱ្យសំរេចបាននូវទស្សនៈវិស័យនៃប្រព័ន្ធព័ត៌មានសុខាភិបាលនៅក្នុងប្រទេសកម្ពុជា។ **គោលបំណង** ទាំងនោះមានៈ

១. ធានាបាននូវការអនុវត្តន៏ខ្ពស់នៃ ប្រ.ព.ស ជាតិ ដោយគោរពតាមស្តង់ដារអន្តរជាតិ និង ទទួលបាននូវការទទួលស្គាល់ និង ការគាំទ្រនៅក្នុងចំណោមអ្នកធ្វើគោលនយោបាយ និង សាធារណៈ ។

២. ធានាបាននូវការសំរេចចិត្តដោយផ្អែកលើភស្តុតាងជាក់ស្តែង តាមរយៈការត្រួតពិនិត្យតាមដាន និងការវាយតំលៃនូវការបំពេញការងារសុខាភិបាល (performance) និងធ្វើឱ្យប្រសើរឡើងការផលិតទិន្នន័យ និង ការផ្សព្វផ្សាយព័ត៌មានតាមរយៈការប្រើប្រាស់នូវការប្រាស្រ័យទាក់ទង និង បច្ចេកវិទ្យាសមស្រប។

៣. ជំរុញឱ្យមាននូវ (availability) ព័ត៌មានប្រកបដោយគុណភាពអំពីប្រជាសាស្ត្រសង្គម សេដ្ឋកិច្ច ជំងឺ មរណៈភាព និង ព័ត៌មានអំពីកត្តាប្រឈមគ្រោះថ្នាក់ និង ធ្វើឱ្យប្រសើរឡើងនូវការសំរបសំរួលនៃការធ្វើផែនការអង្កេត និងការធ្វើអង្កេត (survey planning and implementation)

៤. ពង្រឹងគុណភាពនៃកំណត់ត្រាអ្នកជំងឺ (medical records) ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងករណីជំងឺ និង គុណភាព ភាពលេញលេញ និងទាន់ពេលវេលានៃទិន្នន័យប្រព័ន្ធឃ្លាំមើលជំងឺដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពចំពោះការរាតត្បាត និងទប់ស្កាត់នៃជំងឺឆ្លង។

៥. ធានាបាននូវប្រសិទ្ធិភាព និង ប្រសិទ្ធិភាពតំលៃនៃការថែទាំសុខភាព និង ការបំពេញការងារសុខាភិបាលសាធារណៈ (public health performance) តាមរយៈការគ្របដណ្តប់នៃប្រព័ន្ធព័ត៌មានសុខាភិបាល និង ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទិន្នន័យអំពីហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និង ភ័ស្តុភារ (logistics)។

ផ.យ.ប្រ.ព.ស ២០០៨-២០១៥ មានសមាសភាគសំខាន់ប្រាំដែលយកចេញពីក្របខ័ណ្ឌនៃបណ្តាញរង្វាស់សុខភាព។ សមាសភាគនេះរួមមានៈ

១- គោលនយោបាយ និង ធនធាននៃ ប្រ.ព.ស

២- ការគ្រប់គ្រងទិន្នន័យ និង ការប្រើប្រាស់

៣- កំណត់ត្រាជំងឺ និង សុខភាព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺ

៤- ការធ្វើជំរឿន ការចុះបញ្ជីអត្រានុកូលដ្ឋាន និង ការធ្វើអង្កេត (population based surveys)

៥- ការងាររដ្ឋបាលនៃសេវាសុខាភិបាល និង ប្រព័ន្ធទ្រទ្រង់ (health service administration)

នៅក្រោមសមាសភាគនីមួយៗ ផែនការយុទ្ធសាស្ត្របានបញ្ជាក់អំពីគោលដៅជាក់លាក់ចំនួន ១២។ **គោលដៅ** ទាំងនោះមានៈ

១- បង្កើនទិន្នន័យសុខាភិបាលដែល មានភាពត្រឹមត្រូវ ទាន់ពេលវេលា និង ពេញលេញ ពីមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន។

២- លើកកំពស់គុណភាពព័ត៌មានសុខាភិបាល

៣- ពង្រឹងការប្តេជ្ញា ការសំរបសំរួល និងធនធានសំរាប់ ប្រព័ន្ធព័ត៌មានសុខាភិបាល

៤- បង្កើនការចែករំលែក ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យ

៥- បង្កើនទិន្នន័យ (availability) ប្រជាជននិង ប្រជាសាស្ត្រ-សង្គម (socio-demographic) និង ការប្រើប្រាស់ នៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល និង ថ្នាក់រដ្ឋបាលដើម្បីលើកកំពស់សុខភាព និង ការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រងនៃការផ្តល់សេវា។

៦- ធ្វើឱ្យប្រសើរឡើងនូវការគ្របដណ្តប់ និង ការប្រើប្រាស់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមានមូលហេតុនៃការស្លាប់នៅមូលដ្ឋានសុខាភិបាល និង នៅក្នុងសហគមន៍ ។

៧- បង្កើនទិន្នន័យអង្កេត (availability) រួមមានជំងឺមិនឆ្លង និង កត្តាប្រឈមគ្រោះថ្នាក់

៨- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកត់ត្រាអ្នកជំងឺ ការរក្សាទុកដាក់ និងប្រព័ន្ធបញ្ចូលទិន្នន័យ នៅមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន

៩- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដានជំងឺ ការធ្វើរោគវិនិច្ឆ័យ ការរាយការណ៍បន្ទាន់នៃករណីជំងឺ និង ការឆ្លើយតបទាន់ពេលវេលាទៅនឹងការរាតត្បាតនៃជំងឺ

១០- ពង្រឹងការរាយការណ៍ករណីជំងឺ ការត្រួតពិនិត្យតាមដាន និងការឆ្លើយតបទៅនិងជំងឺមិនឆ្លង (មិនរាប់បញ្ចូលគ្រោះថ្នាក់ចរាចរ និង របួសទេ)

១១- ពង្រីកការចូលរួមរបស់វិស័យឯកជននៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលជាតិ និង

១២- ពង្រីក និង ធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យ អំពីហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និង ភ័ស្តុភារ ។

ផែនការយុទ្ធសាស្ត្រនេះក៏មានរៀបរាប់ផងនូវផែនការសកម្មភាព លទ្ធផលរំពឹងទុក ពេលវេលា ការទទួលខុសត្រូវ និង តំរូវការធនធាននានា។ មានការទទួលស្គាល់ថា ផ.យ.ប្រ.ព.ស ២០០៨-២០១៥ នេះអាចអនុវត្តទៅបាន ដោយជោគជ័យអាស្រ័យដោយៈ ១- ការឯកភាពទាំងស្រុងពីរាជរដ្ឋាភិបាល ដោយមានការគាំទ្រ ខាងនយោបាយ និងច្បាប់ ។ ២- ផែនការនេះទាមទារឱ្យមានថវិកាគ្រប់គ្រាន់ និង ការគាំទ្រពីរដ្ឋាភិបាលនិង ដៃគូអភិវឌ្ឍន៍សុខាភិបាលសំខាន់ៗ។ ៣- វាចាំបាច់ណាស់ដែលអង្គការនានា និង ដៃគូដែលចូលរួមនៅក្នុងការអនុវត្តន៏ នូវផែនការយុទ្ធសាស្ត្រនេះ រក្សានូវបណ្តាញការងារឱ្យបានល្អ ហើយនិងអនុម័តយន្តការសំរបសំរួលចាំបាច់ ៤- ផែនការនេះត្រូវការធ្វើការប្រាស្រ័យទាក់ទងគ្នាឱ្យបានទូលំទូលាយ ហើយមានការយល់ដឹងពីដៃគូនានា ពី សមាគមវិជ្ជាជីវៈ ប្រព័ន្ធផ្សព្វផ្សាយ និង ប្រជាពលរដ្ឋ។ ៥- ផែនការនេះត្រូវតែគាំទ្រគោលនយោបាយ និង សកម្មភាពឱ្យមានប្រសិទ្ធភាពបំផុតនៅថ្នាក់ជាតិ និង ថ្នាក់ក្រោម។ ៦- វាត្រូវធានាឱ្យបាននូវអភិក្រមស្តង់ដារ ដើម្បីគ្រប់គ្រងទិន្នន័យ និង ព័ត៌មានសុខាភិបាល។ ចុងបញ្ចប់ ផែនការនេះគួរតែត្រូវបានអនុវត្តយ៉ាងពេញលេញ ដើម្បីអាចផ្តល់នូវព័ត៌មានដែលត្រូវការសំរាប់ធ្វើការសំរេចចិត្តបានត្រឹមត្រូវ។

# សេចក្ដីផ្ដើម ៤

ផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល ២០០៨-២០១៥ នេះគឺជាផលិតផលដែលបានបង្កើតឡើងតាមរយៈការធ្វើការវាយតំលៃនៃប្រព័ន្ធព័ត៌មានសុខាភិបាល ហើយនិង ការពិគ្រោះពិភាក្សាបែបទូលាយជាមួយដៃគូនានា ដែលបានចាប់ផ្ដើមឡើងនៅពាក់កណ្ដាលឆ្នាំចុងក្រោយនៃឆ្នាំ ២០០៦ ហើយបានសំរេចនៅខែធ្នូ ២០០៧។ ជំនួយថវិកា និង បច្ចេកទេសត្រូវបានផ្ដល់ឱ្យដោយបណ្ដាញរង្វាស់សុខភាព និង អង្គការសុខភាពពិភពលោកសំរាប់ធ្វើការវាយតំលៃ ប្រ.ព.ស និង ការរៀបចំ ផ.យ.ប្រ.ព.ស ២០០៨-២០១៥។ ចាប់តាំងពីក្រសួងសុខាភិបាលបានចាប់ផ្ដើមរៀបចំអភិវឌ្ឍផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ដែលគ្រោងនិងផ្សព្វផ្សាយនៅខែ មីនា ឆ្នាំ ២០០៨ នោះមានការសង្ឃឹមទុកថា ផ.យ.ប្រ.ព.ស និង បញ្ចប់បន្ទាប់ពី ផែនការយុទ្ធសាស្ត្រសុខាភិបាល។ តែទោះជាយ៉ាងណាក៏ដោយ មានកត្តាគន្លឹះពីរដែលពាក់ព័ន្ធដល់ការសំរេចនូវសេចក្ដីសង្ឃឹមនេះ។ ទីមួយ គឺប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាប្រទេសរលកទីមួយ (first wave country) ក្នុងការអនុវត្តន៏នូវក្របខ័ណ្ឌនៃបណ្ដាញរង្វាស់សុខភាពនៅទូទាំងពិភពលោក។ ទីពីរ ក្រសួងសុខាភិបាលឯកភាពថានៅពេលដែល ផែនការយុទ្ធសាស្ត្រ ប្រ.ព.ស ត្រូវបានបង្កើតឡើង ត្រូវថិតនៅជាផែនការព្រាងនៅឡើយ ដែលត្រូវធ្វើការពិនិត្យកែសំរួលឡើងវិញបន្ទាប់ពីផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ បានបញ្ចប់ ដើម្បីធានាបានថាផែនការទាំងពីរនេះ វាស៊ីគ្នា។ ដំណើរការនៃការពិនិត្យឡើងវិញនេះ និងប្រព្រឹត្តិទៅបន្ទាប់ពីការផ្សព្វផ្សាយនៃផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥។ ផ.យ.ប្រ.ព.ស នេះប្រៀបបាននិងត្រីវិស័យក្នុងការតំរង់ទិសរាល់សកម្មភាពនានាដែលទាក់ទងទៅនិងការអភិវឌ្ឍន៏បន្ថែមទៀតនៃ ប្រ.ព.ស នៅក្នុងប្រទេសនៅក្នុងរយៈពេលប្រាំបីឆ្នាំ ខាងមុខ។ ផែនការយុទ្ធសាស្ត្រត្រូវបានតាក់តែងឡើងដោយមានបង្ហាញពីគោលដៅ យុទ្ធសាស្ត្រ និង គោលដៅចំណុច និងបទអន្តរាគមន៏ ដែលឆ្លើយតបទៅនិងភាពខ្សោយ និង កង្វះខាត ដែលបានរកឃើញនៅពេលធ្វើការវាយតំលៃ ប្រ.ព.ស បែបទូលាយដោយមានការចូលរួមពីដៃគូជាច្រើន។ ដោយមានការវាយតំលៃបើកទូលាយបែបនេះ ទើបផែនការយុទ្ធសាស្ត្រនេះមានវិសាលភាពធំដោយរួមមានការពង្រីក និង ស៊ីជំរៅទៅលើប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និង បន្ទាប់មកការអនុម័តិនូវចំណាត់ថ្នាក់អន្តរជាតិនៃជំងឺ ( ICD-10: International Classification of Diseases ) នៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល។ លក្ខណៈពិសេសនៃការអភិវឌ្ឍន៏នៃ ផ.យ.ប្រ.ព.ស គឺការចូលរួមយ៉ាងទូលាយនូវដៃគូដែលពាក់ព័ន្ធនានាជាច្រើនរួមមានតំណាងនៃក្រសួងមហាផ្ទៃ ក្រសួងផែនការ នាយកដ្ឋានសុខាភិបាលនានា កម្មវិធីជាតិ មន្ទីរសុខាភិបាលខេត្ត ហើយនិងដៃគូអភិវឌ្ឍន៏សុខាភិបាល រួមមានម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល។ ហេតុដូច្នេះហើយ ផ.យ.ប្រ.ព.ស តំណាងឱ្យការមូលមតិគ្នាបែបទូលាយនៅ

ក្នុងផ្នែកសុខាភិបាល និង ផ្នែកដ៏ទៃទៀតអំពីតំរូវការចាំបាច់នូវ ប្រ.ព.ស ក៏ដូចជាតំរូវការនូវប្រភពបន្ថែមនៃទិន្នន័យ ដូចជាការធ្វើជំរឿន ការធ្វើអង្កេតគ្រួសារ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដែលអាចដើរតួនាទីសំខាន់ឈ្មោះទៅពង្រឹង ការធ្វើផែនការកម្មដោយផ្អែកលើភស្តុតាងជាក់លាក់ ការអនុវត្តន៏ ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃនូវការផ្តល់សេវាសុខាភិបាលនៅកម្ពុជា។

គោលបំណងនៃ ផ.យ.ប្រ.ព.ស នេះគឺកំណត់ថាតើការគ្រប់គ្រងនៃព័តិមានសុខាភិបាលពីប្រភពនានាអាចជួយសំរេចបានគោលបំណង និង គោលដៅរបស់វិស័យសុខាភិបាលនៅក្នុងរយៈពេលមធ្យមដែរឬទេ។ ប្រព័ន្ធសុខាភិបាលទំនើបត្រូវការព័តិមានសុខាភិបាលមួយដែលត្រឹមត្រូវ និង អាចយកមកប្រើបានភ្លាម១។ វាមានសារៈសំខាន់ណាស់ក្នុងការលើកកំពស់ការថែទាំអ្នកជំងឺ ការលើកកំពស់ការបំពេញការងារនៅក្នុងប្រព័ន្ធសុខាភិបាល និងចូលរួមចំណែកលើកកំពស់សុខភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប។

ផ.យ.ប្រ.ព.ស ក៏បានបង្ហាញផងដែរអំពីប្រវត្តិសង្ខេបរបស់ ប្រ.ព.ស បរិបទនៃប្រ.ព.ស ជាតិ ហើយនិងលទ្ធផលនៃការវាយតំលៃ ប្រ.ព.ស រួមមានភាពខ្លាំង និង ចំណុចខ្វះខាតនានានៅក្នុងផ្នែកទី៥។ នៅផ្នែកទី ៦ បានលើកឡើងអំពីសន្និទានសំរាប់ធ្វើផែនការយុទ្ធសាស្រ្ត ការគ្រប់គ្រងទិន្នន័យ លទ្ធផលរំពឹងទុក ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យនៅទូទាំងវិស័យសុខាភិបាល និង វិស័យផ្សេងទៀត។ នៅផ្នែកទី ៧ មានបង្ហាញអំពីចក្ខុវិស័យ គោលបំណង ហើយនិងគោលដៅ។ នៅផ្នែកទី ៨ បង្ហាញអំពីសមាសភាគគន្លឹះនៃយុទ្ធសាស្រ្តដែលផ្សារភ្ជាប់ទៅនិងសមិទ្ធផលរបស់គោលដៅនានា និងផ្តោតទៅលើការអនុវត្តន៏ និង សកម្មភាពនានាដោយមានបញ្ជាក់ពីពេលវេលា ការទទួលខុសត្រូវ និង ការប៉ាន់ស្មានថវិកាដែលត្រូវការ។ នៅផ្នែកទី ៩ គូសបញ្ជាក់អំពីយន្តការនៃការត្រួតពិនិត្យតាមដាន និង វាយតំលៃ សំរាប់ធ្វើការវាយតំលៃទៅលើវឌ្ឍនៈភាព និង លទ្ធផលរបស់ផែនការយុទ្ធសាស្រ្ត។ នៅផ្នែកទី ១០ មានបរិយាយអំពីលក្ខ័ណដែលត្រូវមាន ជាមុនដើម្បី អាចសំរេចបានជោគជ័យ ដែលនិយាយទៅដល់ ការសំរបសំរួលនៅក្នុងចំណោមស្ថាប័ននានា សមត្ថភាពធនធានមនុស្ស ហើយនិងការប្តេជ្ញាខាងគោលនយោបាយ ហើយចំណែកផ្នែកទី ១១ រៀបរាប់អំពីឧបសម្ព័ន្ធ និង ឯកសារយោង។

# សារបាន ៥

## ១-ប្រវត្តិសង្ខេបនៃប្រព័ន្ធព័ត៌មានសុខាភិបាលជាតិ

ប្រវត្តិនៃ ប្រ.ព.ស ជាតិនៃប្រទេសកម្ពុជាបានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ ១៩៩២ នៅពេលដែល ក្រសួងសុខាភិបាលបានបង្កើតអនុគណៈកម្មការ ប្រ.ព.ស ដោយបញ្ជាក់ពីការទទួលខុសត្រូវនៃការបង្កើតឡើងនូវប្រព័ន្ធព័ត៌មានសុខាភិបាលជាតិ។ តំរូវការនៃ ប្រ.ព.ស ជាតិ បានរីកធំធាត់ឡើងដោយមានការកើនឡើងនូវការទាមទារអំពីស្ថានភាពសុខភាព ហើយនិងការប្រើប្រាស់ព័ត៌មានពីបណ្តាអ្នកប្រើប្រាស់នានា ដូចជានាយកដ្ឋាននានានៃក្រសួងសុខាភិបាល កម្មវិធីជាតិ និងមន្ទីរសុខាភិបាលខេត្ត-ក្រុង។ ប្រ.ព.ស ថ្មីនេះបន្ទាប់មកត្រូវបានប្រកាស ផ្សព្វផ្សាយជាផ្លូវការនៅក្នុងឆ្នាំ ១៩៩៣ ដោយមានការដាក់បញ្ចូលឱ្យប្រើប្រាស់នៅក្នុងខេត្តមួយចំនួន ហើយបានគ្របដណ្តប់នៅទូទាំងប្រទេសនៅក្នុងខែកុម្ភៈឆ្នាំ ១៩៩៥។

ប្រ.ព.ស ថ្មីនេះបានផ្តោតទៅលើការប្រមូលទិន្នន័យអំពីសកម្មភាពផ្តល់សេវាជាប្រចាំ ហើយនិងបញ្ហាសុខភាព ដែលត្រូវបានរាយការណ៍ពីគ្រប់លំដាប់ថ្នាក់នៃមូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ ជាពិសេសមន្ទីរពេទ្យ និង មណ្ឌលសុខភាព នៃប្រព័ន្ធសុខាភិបាលជាតិ។ តែទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះមិនបានប្រមូលទិន្នន័យអំពីភ័ស្តុភារ ការងាររដ្ឋបាល ហិរញ្ញវត្ថុ និង ស្ថិតិអត្រានុកូលដ្ឋានទេ។ ទិន្នន័យបានបំបែកទៅតាមក្រុមអាយុ និងទីតាំងភូមិសាស្ត្រ ហើយព័ត៌មានទៅតាមភេទមានតែចំពោះ ការពិនិត្យពិគ្រោះជំងឺក្រៅសរុប អ្នកជំងឺសំរាកពេទ្យ និង លទ្ធផលមន្ទីរពិសោធន៍នៃជំងឺគ្រុនចាញ់ប៉ុណ្ណោះ។

ជាប់តាំងពីពេលចាប់ផ្តើមនៃ ប្រ.ព.ស ថ្មីនេះមក ប្រ.ព.ស បានឆ្លងកាត់ការពិនិត្យកែលំអរឡើងវិញជាច្រើនដងគឺនៅឆ្នាំ ១៩៩៦, ១៩៩៩ និង នៅឆ្នាំ ២០០៣។ ការពិនិត្យឡើងវិញនៅក្នុងឆ្នាំ ១៩៩៦ ត្រូវបានទាមទារឱ្យមានការកែសំរួលដើម្បីឆ្លើយតបទៅនិងផែនការគ្របដណ្តប់សុខាភិបាល ដែលបានកំណត់សេវាសុខាភិបាលដែលត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលនីមួយៗ ផ្អែកលើមូលដ្ឋានភូមិសាស្ត្រ និងចំនួនប្រជាជន។ នៅក្នុងឆ្នាំ ១៩៩៩ មានការកែប្រែតិចតួចត្រូវបានធ្វើឡើងដើម្បីលើកកំពស់ការរាយការណ៍នៃអាំងឌីកាទ័រគន្លឹះមួយចំនួន។

ការពិនិត្យកែសំរួលចុងក្រោយនៅក្នុងឆ្នាំ ២០០៣ ត្រូវបានធ្វើឡើងដើម្បីកំណត់អាំងឌីកាទ័របន្ថែមដែលបានទាមទារដោយ កម្មវិធីជាតិនានា និង មូលដ្ឋានសុខាភិបាល សំរាប់ធ្វើការត្រួតពិនិត្យតាមដាន និងធ្វើការវាយតំលៃ ហើយនិងលុបបំបាត់ចោលអាំងឌីកាទ័រដែលមិនប្រើប្រាស់។ កំណត់សំគាល់គួរឱ្យចាប់អារម្មណ៍នៃការពិនិត្យឡើងវិញទាំងបីលើក នេះគឺការធ្វើឡើងតាមបែបពិគ្រោះយោបល់ និង ការចូលរួមពីដៃគូទាំងអស់។

## ក- បរិបទគោលនយោបាយនៃ ប្រ.ព.ស ជាតិ

គំនិតផ្ដួចផ្ដើមជាច្រើនរបស់រាជរដ្ឋាភិបាល ហើយនិងក្រសួងសុខាភិបាល ទាមទារឱ្យមានការពិចារណា នៅពេលធ្វើការអភិវឌ្ឍន៍នៃ ផ.យ.ប្រ.ព.ស ២០០៨-២០១៥នេះ។ គំនិតផ្ដួចផ្ដើមទាំងនេះរួមមាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ហើយនិង ផែនការយុទ្ធសាស្ត្រស្ថិតិ ២០០២-២០០៧ នៃវិទ្យាស្ថានជាតិស្ថិតិ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ លើកដំបូងរបស់រាជរដ្ឋាភិបាលគឺជាឯកសារដែលមានបញ្ជាក់អំពី គោលបំណងអាទិភាព ហើយនិងយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ហើយនិងសំរេចបានគោលដៅសហសវត្សរកម្ពុជា និងគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមសំរាប់ផលប្រយោជន៍របស់ ប្រជាជនកម្ពុជាគ្រប់រូប។ ផែនការនេះមានទំនោរតឹមយុទ្ធសាស្ត្ររបស់វិស័យនានា និង វដ្ដនៃផែនការកម្ម ឱ្យស្របនិងចក្ខុវិស័យយូរអង្វែង ក៏ដូចគ្នានិងតំរងទិសដៃគូអភិវឌ្ឍន៍នានា ឱ្យតឹមនិងមានសុខដុមនីកម្មនៃការខិតខំប្រឹងប្រែងដើម្បីឈ្ពោះទៅកាន់ភាពប្រសើរឡើងនូវប្រសិទ្ធិភាពជំនួយ ហើយនិង ការផ្ទេរនៃធនធាន (aid effectiveness and net resource transfer) (ក្រសួងផែនការ ២០០៦)។

ការងារអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកែទំរង់វិស័យសុខាភិបាល ហើយនិង ការធ្វើឱ្យប្រសើរឡើងនូវសេវាសុខាភិបាលនៅក្នុងផែនការនេះរួមមានៈ

- ពង្រីកមូលដ្ឋានសុខាភិបាលតាមរយៈការសាងសង់ ឬការជួសជុល ដូចជាមន្ទីរពេទ្យ មណ្ឌលសុខភាព នៅទីជនបទ។
- ពង្រីក និង ពង្រឹងវិធីសាស្ត្រប្រកបដោយនិរន្តភាពនៃការផ្ដល់សេវា ដើម្បីជួយប្រជាជនក្រីក្រអាចប្រើប្រាស់សេវាថែទាំសុខភាពសាធារណៈបាន។
- ជំរុញលើកទឹកចិត្ត និងធ្វើយ៉ាងណាឱ្យផ្នែកឯកជនចូលរួមក្នុងការផ្ដល់សេវាថែទាំសុខភាព ទាំងនៅទីក្រុង និងនៅជនបទ។
- ធ្វើការយកចិត្តទុកដាក់ជាពិសេសដល់ការរីករាលដាលនៃជំងឺអេដស៍ ជាពិសេសចំពោះគ្រួសារ តាមរយៈការខិតខំធ្វើការអប់រំ និង ផ្ដល់ព័ត៌មាន។

## ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥

ផ.យ.ប្រ.ព.ស ត្រូវបានអភិវឌ្ឍន៍ឡើងដោយផ្អែកលើចក្ខុវិស័យ បេសកកម្ម គុណតំលៃ និង គោលការណ៏ការងារនៃផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ នៅក្នុងរយៈពេល ៨ ឆ្នាំដូចខាងក្រោមនេះ

## ចក្ខុវិស័យ

" លើកកំពស់ការអភិវឌ្ឍន៍ប្រកប ដោយនិរន្តភាពនៃវិសយ័សុខាភិបាល ដើម្បីភាពកាន់តែប្រសើរឡើងនៃសុខភាព និងសុខុមាលភាពរបស់ ប្រជាជនទាំងអស់ពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៏វិសយ័សេដ្ឋកិច្ច និងសង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។" ។

## បេសកកម្ម

" ផ្តល់មគ្គុទេសភាព (stewardship) សំរាប់វិសយ័សុខាភិបាលទាំងមូល និងធានាអោយមានបរិយាកាសគាំទ្រដល់ការបង្កើនតំរូវការផ្អែកសុខភាពនិងលទ្ធភាពទទួលយកសេវាថែទាំមានគុណភាព ប្រកបដោយសមធមិ ដើម្បីឱយប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបាននូវកំរិតអតិបរមា លើផ្នែកសុខភាពនិង សុខុមាលភាព " ។

សេចក្តីថ្លែងអំពីបេសកកម្មនេះគូសបញ្ជាក់ អំពីការប្តេជ្ញារបស់ក្រសួងសុខាភិបាល ដែលផ្តោតទៅលើ ការអនុវត្តន៏ "មគ្គុទេសភាព" សំរាប់ការផ្តល់សេវាកម្មលើគ្រប់ផ្នែកទាំងអស់ទូទាំងវិសយ័សុខាភិបាល ។ បេសកកម្មនេះបានរំលេចឱយឃើញផងដែរអំពី កំរិតអតិប្បរមានៃស្ថានភាពសុខភាព និងសុខុមាលភាពរបស់ប្រជាជន ដែលប្រពន្ធ័សុខាភិបាលខិតខំប្រយុទ្ធដើម្បីលើកស្ទួយនោះ គឺប្រពន្ធ័សុខាភិបាលដែលបានដាក់ "បង្កើនតំរូវការផ្អែកសុខភាព គុណភាពកាន់តែប្រសើរ និងលើកស្ទួយលទ្ធភាពមកទទួលយកសេវា" នៅចំកណ្តាលបេះដូងនៃការផ្តល់សេវាថែទាំសុខភាព ។

## គុណតំលៃ

" សមធមិ និង សិទ្ធសុខភាព សំរាប់ប្រជាជនកម្ពុជាទាំងអស់ " ។

## គោលការណ៏

បង្កើនប្រសិទ្ធភាព ការទទួលខុសត្រូវ គុណភាព និងសមធមិ ទូទាំងប្រពន្ធ័សុខាភិបាលអាច នឹង សំរេចបាន តាមរយៈការប្រព្រឹត្តិវិធានសីលធមិ ជំនឿដ៏រឹងមាំ និងការប្តេជ្ញាចំពោះគោលបំណងរួម របស់បុគ្គលទាំងអស់

ដែល កំពុងបំពេញការងារក្នុងការថែទាំសុខភាព។ ដូច្នេះសកម្មភាពពីមួយថ្ងៃមួយទៅមួយថ្ងៃរបស់មន្ត្រីគ្រប់គ្រង និងបុគ្គលិក នៅគ្រប់ផ្នែកទាំងអស់ទូទាំងអង្គភាពគ្រប់ថ្នាក់ គប្បីត្រូវបានណែនាំ ដោយគោលការណ៍ ៥ យ៉ាងដូចតទៅ:

| | |
|---|---|
| ១. ការគាំពារសុខភាពសង្គម ពិសេសប្រជាជនក្រីក្រនិងក្រុម ប្រជាជនដែលងាយរងគ្រោះ | លើកស្ទួយវិធីសាស្ត្រគាំទ្រជនក្រីក្រផ្តោតលើការតំរង់ធនធាន ទៅកាន់ជនក្រីក្រ និងក្រុមប្រជាជនដែលមានតំរូវការចាំបាច់ និងទៅកាន់កន្លែងដែលត្រូវការបំផុត ពិសេសតំបន់ជនបទ ដាច់ស្រយ៉ាលនិងទីប្រជុំជនក្រីក្រ។ |
| ២. វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើអតិថិជនក្នុងការផ្តល់សេវាសុខភាព | ផ្តល់សេវាសុខភាព ដោយផ្តោតលើលទ្ធភាពអាចបង់ថ្លៃបាន និង ការទទួលយកបាននៃសេវា សិទ្ធិអតិថិជន ការចូលរួមរបស់សហគមន៍ និងភាពជាដៃគូជាមួយផ្នែកឯកជន។ |
| ៣. វិធីសាស្ត្រសមាហរណកម្មក្នុងការផ្តល់សេវាសុខភាពនិងអន្តរាគមន៍សុខភាពសាធារណៈមានគុណភាពខ្ពស់ | ផ្តល់សេវាថែទាំសុខភាពគ្រប់ជ្រុងជ្រោយរួមមានសេវាបង្ការ ព្យាបាល និង លើកកំពស់សុខភាព ស្របតាមគោលការណ៍ ស្តង់ដារ និង មគ្គុទេសន៍គ្លីនិកជាតិ ដែលអាចទទួលយកបាន តាមរយៈសំណុំសកម្មភាព អប្បបរមា និងសំណុំសកម្មភាព បង្គ្រប់ និងភាពជាដៃគូជាមួយវិសយ័ឯកជន។ |
| ៤. ការគ្រប់គ្រងធនធានមនុស្ស គឺជាសសរទ្រូងនៃប្រព័ន្ធសុខាភិបាលទាំងមូល | មានចរិតប្រតិបត្តិនិងផលិតភាពដែលស្តែងចេញពីសមត្ថភាព ក្រមសីលធម៌ ការបំពេញការងារជាក្រុម ការលើកទឹកចិត្ត បរិយាកាសបំពេញការងារល្អ និង បែបបទរៀនហើយ រៀនទៀត។ |
| ៥. អភិបាលកិច្ចល្អនិងការទទួលខុសត្រូវ | ផ្តល់មគ្គុទេសភាព ដល់វិសយ័សាធារណៈនិងឯកជនដោយ ផ្តោតលើអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិសយ័ផែនការ នីយកម្មមានប្រសិទ្ធភាព ការត្រួតពិនិត្យតាមដានស្នាដៃការ ងារនិងការសំរបសំរួល។ |

ទិសដៅគោលនយោបាយ នៃផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-១៥ បានបញ្ជាក់ច្បាស់ថា "ពង្រឹង និង វិនិយោគនៅក្នុងផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល ហើយនិងការស្រាវជ្រាវសុខភាព ដើម្បីធ្វើការសំរេចចិត្តដោយផ្អែកលើភ័ស្តុតាងជាក់ស្តែង ការធ្វើផែនការ ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃ" ហើយកំណត់ប្រព័ន្ធព័ត៌មានជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំង ៥ ដែលត្រូវដាក់ឱ្យអនុវត្តនៅក្នុងគ្រប់កម្មវិធីសុខ

ភាពទាំងបី ដូចមានបង្ហាញនៅក្នុងក្របខ័ណ្ឌប្រតិបត្តិនៃផែនការយុទ្ធសាស្ត្រខាងក្រោម ។




## ផែនការយុទ្ធសាស្ត្រនៃវិទ្យាស្ថានជាតិស្ថិតិ ២០០២-២០០៧

ផែនការយុទ្ធសាស្ត្រនេះបានអភិវឌ្ឍន៍ឡើងទៅតាមតំរូវការរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ ក្នុងការសំរបសំរួលការត្រួតពិនិត្យតាមដាន និង ការវាយតំលៃនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយនិង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ គោលដៅចំបងនៃផែនការយុទ្ធសាស្ត្រនេះគឺត្រូវ:

- អភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិដែលមានលក្ខណ:សំរបសំរួល និង មានភាពល្អប្រសើរឡើង (a coordinated and improved national statistical system for the country)
- អភិវឌ្ឍន៍សេវាស្ថិតិដែលមានលក្ខណ:ទាន់ពេល ពាក់ព័ន្ធ ឆ្លើយតប និងមានគុណភាព (an NIS statistical service that is timely, relevant, responsive, and respected for its integrity and quality)
- បង្កើនការប្រើប្រាស់នូវស្ថិតិផ្លូវការ (informed and increased use of official statistics)
- ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពស្ថិតអន្តរជាតិ ដែលមានសារ:សំខាន់ចំពោះប្រទេស និង នៅក្នុងតំបន់អាស៊ីអគ្នេយ៍
- បង្ករបរិយាកាសចំពោះស្ថាប័នដោយជួយជំរុញ ការរៀនសូត្រ គំនិតឆ្នៃប្រឌិត និង ការបំពេញការងារខ្ពស់នៅរាល់គ្រប់សកម្មភាពស្ថិតិទាំងអស់

- ទំនុកចិត្ត និង កិច្ចសហការ នៅក្នុងចំណោមអ្នកផ្តល់ទិន្នន័យនៃវិទ្យាស្ថានជាតិស្ថិតិ ហើយនិង
- ទទួលបាននូវការទទួលស្គាល់ និង ការគាំទ្រយ៉ាងពេញទំហឹងចំពោះវិទ្យាស្ថានជាតិស្ថិតិ នៅក្នុងចំណោមអ្នកធ្វើការសំរេចចិត្ត និង សមហគមន៍យ៉ាងទូលំទូលាយ

ផែនការយុទ្ធសាស្ត្រនៃវិទ្យាស្ថានជាតិស្ថិតិ ផ្តល់ឳកាសដ៏វិសេសវិសាលចំពោះ ក្រសួងសុខាភិបាលដើម្បីអភិវឌ្ឍយន្តការរួមសំរាប់កិច្ចសំរបសំរួល ការចែករំលែកទិន្នន័យ ហើយនិងផលិតផលព័ត៌មានដែលមានលក្ខណៈឯកភាព (unified information products)។ សកម្មភាពជាច្រើនដែលបានបរិយាយនៅក្នុង ផ.យ.ប្រ.ព.ស បច្ចុប្បន្ននេះ ដោយសំដៅទៅដល់ទិន្នន័យជំងឺ ទិន្នន័យមរណៈភាព ហើយនិង ការប្រើប្រាស់នូវព័ត៌មាន បានកំណត់ជាបណ្តាញ (channels) នៃសកម្មភាពសំរបសំរួល ហើយនិងផលិតផលព័ត៌មានច្បាស់លាស់ដែលអាចផ្សារភ្ជាប់គ្នារវាងផែនការទាំងពីរ ហើយនិងបង្កើតគំរោងការងារឯកភាពដែលមានលក្ខណៈយូរអង្វែង ហើយ និងកម្មវិធីសំរាប់បង្កើនការសំរបសំរួលរវាងក្រសួងសុខាភិបាល ហើយនិងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

## ខ-ការវាយតំលៃនៃ ប្រ.ព.ស ជាតិ

ការវាយតំលៃនេះជាផ្នែកមួយនៃការអភិវឌ្ឍន៍នូវ ផ.យ.ប្រ.ព.ស ២០០៨-២០១៥ ដែលនាយកដ្ឋានផែនការនៃក្រសួងសុខាភិបាល បានរៀបចំឡើងដើម្បីវាយតំលៃពីភាពខ្លាំង ចំណុចខ្វះខាត នៃ ប្រ.ព.ស ហើយនិងបង្កើតជារូបមន្តដើម្បីអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ។ កំលាំងជំរុញចំពោះការធ្វើការវាយតំលៃនេះត្រូវបានជួយជាជំនួយបច្ចេកទេស និង ថវិកា ដោយបណ្តាញរង្វាស់សុខភាពដែលជាដៃគូសកលនៃក្រសួងសុខាភិបាលនានា អង្គការសុខភាពពិភពលោក ទីភ្នាក់ងារសហប្រជាជាតិដ៏ទៃទៀត ម្ចាស់ជំនួយពហុភាគី និង មូលនិធិឯកជន ដែលបានប្រកាសផ្សព្វផ្សាយកាលពីវិច្ឆកា ឆ្នាំ ២០០៤ ហើយនិងឯកភាពនៅក្នុងខែឧសភា នាឆ្នាំ ២០០៥ នៅឯសភាសុខភាពពិភពលោក។ គោលបំណងចំបងនៃបណ្តាញរង្វាស់សុខភាពគឺដើរតួជាអ្នកជួយសំរួល (catalyst) ដើម្បីបង្កើនភាពមាន (availability) នូវទិន្នន័យសុខាភិបាលដែលមានគុណភាពខ្ពស់ ហើយនិងព័ត៌មាន សំរាប់ធ្វើការសំរេចចិត្ត ដោយផ្អែកលើ ភ័ស្តុតាងជាក់លាក់ ទាំងនៅក្នុងប្រទេស និង នៅលើសកលលោក។

ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជាបានទទួលជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុពី បណ្តាញរង្វាស់សុខភាពនៅខែសីហា ២០០៦ ហើយបានផ្តោតទៅលើផ្នែកការងារសកម្មភាពសំខាន់បួនៈ

(i) ការវាយតំលៃនៃ ប្រ.ព.ស ដោយប្រើឧបករណ៍វាយតំលៃដែលបានអភិវឌ្ឍន៍ដោយបណ្តាញរង្វាស់សុខភាព ហើយឧបករណ៍នេះត្រូវបានសំរបទៅតាមការប្រើប្រាស់នៅក្នុងបរិបទនៃប្រទេសកម្ពុជា

(ii) ការអភិវឌ្ឍន៍នូវ ផ.យ.ប្រ.ព.ស ២០០៨-២០១៥

iii) ពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេសហើយនិង

iv) ការកសាងសមត្ថភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវ ប្រ.ព.ស ជាតិ។

ដើម្បីធ្វើការងារនេះក្រសួងសុខាភិបាលបានបង្កើតក្រុមការងារនៃដៃគូ ប្រ.ព.ស (HIS stakeholder working group: HIS-SWG) ដែលនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល ជាអ្នកសំរបសំរួល ហើយក្រុមការងារនេះរួមមាន តំណាងមកពីកម្មវិធីជាតិនានា ដូចជាកម្មវិធីជាតិប្រយុទ្ធនិងជំងឺអេដស៍ របេង គ្រុនចាញ់ និង សុខភាពមាតា និង កុមារ នាយកដ្ឋានប្រយុទ្ធនិងជំងឺឆ្លង វិទ្យាស្ថានជាតិសុខភាពសាធារណៈ នាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ នាយកដ្ឋានជំរឿន និង អង្កេតនៃវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ តំណាងអង្គការសុខភាពពិភពលោក យូនីសេហ្វ យូអិនអេហ្វភីអេ ហ្ស៊ីធីហ្ស៊ិទ ម៉េឌីខាំ រួមមានអង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសនិង អន្តរជាតិ ដូចជា អង្គការរ៉ាឆា និង យូអរស៊ី។ តួនាទី និងភារកិច្ចរបស់ក្រុមការងារនេះរួមមានៈ

(i) សំរបសំរួល និង គាំទ្រការគ្រប់គ្រងនៃ ប្រ.ព.ស ជាតិ
(ii) ធ្វើការពិនិត្យឡើងវិញនូវស្ថានភាព ប្រ.ព.ស ហើយផ្តល់អានុសាសន៍ដល់ក្រសួងសុខាភិបាលដើម្បីធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍន៍ឧបករណ៍ព័ត៌មានសមស្រប។
(iii) លើកកំពស់ការប្រើប្រាស់នូវប្រ.ព.ស សំរាប់ធ្វើការសំរេចចិត្តដោយផ្អែកលើភ័ស្តុតាងជាក់ស្តែង ធ្វើផែនការ និង ការគ្រប់គ្រង
(iv) ផ្តល់ជំនួយបច្ចេកទេស និង អានុសាសន៍អំពីស្ថិតិប្រជាសាស្ត្រសង្គម និងសុខភាព

នៅក្នុងខែតុលា ឆ្នាំ ២០០៦ ការិយាល័យព័ត៌មានសុខាភិបាលនៃនាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាលបានរៀបចំសិក្ខាសាលារយៈពេលបីថ្ងៃ ដែលចូលរួមដោយអ្នកផលិត និង អ្នកប្រើប្រាស់ស្ថិតិសុខាភិបាលមកពីស្ថាប័ននានាជាច្រើន (នាយកដ្ឋាននៃក្រសួងសុខាភិបាល កម្មវិធីជាតិ វិទ្យាស្ថានជាតិ មន្ទីរសុខាភិបាលខេត្ត-ក្រុងទាំង ២៤ ដៃគូអភិវឌ្ឍន៍សុខាភិបាល វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ នាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ) ដើម្បីវាយតំលៃ ប្រ.ព.ស ជាតិ។ នេះគឺជាសិក្ខាសាលាលើកដំបូងដែលបានរៀបចំឡើង ដោយប្រើឧបរណ៍វាយតំលៃរបស់បណ្តាញរង្វាស់សុខភាព តាមរយៈការផ្តល់ជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុពី បណ្តាញរង្វាស់សុខភាព។ សមាសភាគទាំង ៦នៃ ប្រ.ព.ស ត្រូវបានវាយតំលៃៈ ធនធាន អាំងឌីកាទ័រ ប្រភពទិន្នន័យ ការគ្រប់គ្រងទិន្នន័យ ផលិតផលព័ត៌មាន ហើយនិងការផ្សព្វផ្សាយ និង ការប្រើប្រាស់។ តារាងខាងក្រោមបង្ហាញពី លទ្ធផលនៃការវាយតំលៃ។

## តារាងសង្ខេបលទ្ធផលនៃការវាយតំលៃ

| ប្រភេទចំបង | ភាគរយ | យោបល់ |
|---|---|---|
| លក្ខណៈទូទៅ | | **សមាសភាពនៃ ប្រ.ព.ស** |
| ធនធាន | 40% | ទាបជាងគេទីពីរ ហើយជាផ្នែកសំខាន់ |
| អាំងឌីកាទ័រ | 55% | មានតែមិនគ្រប់គ្រាន់ |
| ប្រភពទិន្នន័យ | 49% | ជាផ្នែកសំខាន់ |
| ការគ្រប់គ្រងទិន្នន័យ | 38% | ពិន្ទុទាបជាងគេហើយជាផ្នែកសំខាន់ |
| ផលិតផលព័តិមាន | 67% | គ្រប់គ្រាន់ |
| ការផ្សព្វផ្សាយ និង ការប្រើប្រាស់ | 58% | គ្រប់គ្រាន់ តែមានបញ្ហាខ្លះ |
| ផ្នែកទី ១ | | **ធនធាន** |
| គោលនយោបាយ និង ផែនការ | 35% | ត្រូវការសកម្មភាពសំខាន់ៗជាច្រើនៈ ច្បាប់ ផែនការយុទ្ធសាស្រ្តស្ថិតិនិង គណៈកម្មការប្រ.ព.ស នៃផ្នែកនានា |
| ស្ថាប័នប្រ.ព.ស ធនធានមនុស្ស និងហិរញ្ញវត្ថុ | 38% | ខ្វះខាតធនធានមនុស្សច្រើន |
| ហេដ្ឋារចនាសម្ព័ន្ធ ប្រ.ព.ស | 50% | មានតែមិនគ្រប់គ្រាន់ |
| ផ្នែកទី២ | | **អាំងឌីកាទ័រសំខាន់ៗ** |
| អាំងឌីកាទ័រ | 62 [before 55%] | មានតែមិនគ្រប់គ្រាន់ |
| ផ្នែកទី ៣ | | **ប្រភពទិន្នន័យ** |
| A. ជំរឿន | 44% | បង្កើនសមត្ថភាពនៅជំរឿនលើកក្រោយ (២០០៨) |
| B. ស្ថិតិអត្រានុកូលដ្ឋាន | 42% | ប្រើចំណាត់ថ្នាក់ ICD-10 ជំងឺនៅមន្ទីរពេទ្យ និងនៅក្រសួងមហាផ្ទៃ digitalization at MoI |
| C. អង្កេត | 64% | ប្រភពដ៏សំខាន់ តែត្រូវការការសំរបសំរួលល្អប្រសើរ |
| D. កំណត់ត្រាជំងឺ និង សុខភាព | 43% | |
| E. កំណត់ត្រាសេវាសុខាភិបាល | 41% | សេវាសាធារណៈមានកំរឹតទាប មិនគ្របដណ្តប់ផ្នែកឯកជន |
| F. កំណត់ត្រារដ្ឋបាល | 63% | |
| ផ្នែកទី ៤ | | **ការគ្រប់គ្រងទិន្នន័យ** |
| ការគ្រប់គ្រងទិន្នន័យ | 23% [before 36%] | ធ្វើការវិនិយោគទៅលើធនធានមនុស្សនៃ ប្រ.ព.ស ធ្វើការបណ្តុះបណ្តាលមន្រ្តីគ្រប់គ្រង និងគ្លីនិក បង្កើតឃ្លាំងស្តុកទិន្នន័យសុខាភិបាលនៅថ្នាក់កណ្តាល |

| ផ្នែកទី ៥ | | ផលិតផលព័ត៌មាន |
|---|---|---|
| ប្រភេទ | | |
| វិធីប្រមូលទិន្នន័យ | 62% | |
| ពេលវេលា | 66% | |
| រយៈពេល Periodicity | 60% | |
| ភាពស៊ីគ្នា/ភាពពេញលេញ | 58% | |
| ភាពជាតំណាង/ភាពសមស្រប | 59% | |
| ការបំបែកទិន្នន័យ Disaggregation | 64% | |
| វិធីប៉ាន់ស្មាន/តំលាភាព | 100% | |
| ប្រភេទ | | |
| ស្ថានភាពសុខភាព: មរណៈភាព | 66% | |
| ស្ថានភាពសុខភាព: ជំងឺ | 65% | |
| ប្រព័ន្ធសុខាភិបាល | 61% | |
| កត្តាប្រឈមគ្រោះថ្នាក់ | 66% | |
| គុណភាពអាំងឌីកាទ័រសុខាភិបាលជារួម | 67% | |
| ផ្នែកទី ៦ | | ការផ្សព្វផ្សាយ និង ការប្រើប្រាស់ |
| ការវិភាគ និង ការប្រើប្រាស់ព័ត៌មាន | 63% | ត្រូវការកែលំអ Need for improvement |
| គោលនយោបាយ និង ការតស៊ូមតិ | 60% | ត្រូវការកែលំអ |
| ការធ្វើផែនការ និង ការកំណត់អាទិភាព | 59% | ពង្រឹងការប្រើប្រាស់ទិន្នន័យសំរាប់ធ្វើផែនការ និង ការត្រួតពិនិត្យតាមដាន |
| ការបែងចែកធនធាន | 41% | ត្រូវការការវិនិយោគទៀងទាត់ និង និរន្តភាព |
| ការអនុវត្តន៍/សកម្មភាព | 68% | |

ចេញពីសំណួរទាំង២២៣ ដែលបានវាយតំលៃនៅក្នុងសិក្ខាសាលា ក្រុមការងារ ប្រ.ព.ស បានរកឃើញបញ្ហាចំនួន ៧៧ ដែលត្រូវយកចិត្តទុកដាក់។ បញ្ហាទាំងនេះត្រូវបានកំណត់ជាអាទិភាពទៅតាមសារៈសំខាន់ និងលទ្ធភាព ដែលអាចធ្វើបាន (ឧបសម្ព័ន្ធ ១) នៅពេលធ្វើសិក្ខាសាលារយៈពេលបីថ្ងៃនៅខែឧសភា ២០០៧។ ជាលទ្ធផលនៃសិក្ខាសាលានេះ បានកំណត់គោលបំណងចំនួន ៥ និង គោលដៅចំនួន ៣៧ ដែលក្រោយមកបាន សំរិតសំរាំងមកត្រឹមតែ ១២គោលដៅ។ បន្ថែមពីនេះទៀត សិក្ខាសាលារយៈពេលមួយថ្ងៃបានធ្វើឡើងនៅក្នុងខែមីនា ២០០៧ ដោយមានជំនួយបច្ចេកទេសពីលោកវេជ្ជ. យ៉ុក ឈីង ឆុង ទីប្រឹក្សាប្រព័ន្ធព័ត៌មានសុខាភិបាល ប្រចាំតំបន់

ប៉ាស៊ីហ្វិកខាងលិច ដើម្បីផ្តល់ការណែនាំអំពីបែបបទ និង ការកសាងផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល រួមមាន គ្រោងនៃ ផ.យ.ប្រ.ព.ស វិធីសាស្ត្រ និង ការពិនិត្យឡើងវិញនូវ ប្រ.ព.ស បច្ចុប្បន្ន។ បញ្ហាផ្សេងទៀត ដែលបានពិភាក្សារួមមានការប្រមូលទិន្នន័យត្រួតគ្នានៅថ្នាក់នានា ការរួមបញ្ចូលគ្នានៃព័ត៌មានសុខាភិបាល (ជាពិសេសការបង្កើតឃ្លាំងស្តុកទិន្នន័យនៅក្រសួងសុខាភិបាល) គុណភាពទិន្នន័យ និង គោលនយោបាយ និង ច្បាប់នៃ ប្រ.ព.ស។

# សន្និដ្ឋាន ៦

**ព័ត៌មានសុខាភិបាល:** មានសារៈសំខាន់ណាស់ សំរាប់ត្រួតពិនិត្យតាមដានការបំពេញការងារ (សមិទ្ធផល)នៅក្នុងវិស័យសុខាភិបាល ហើយនិងសំរាប់ធ្វើការសំរេចចិត្តលើការថែទាំសុខភាពឱ្យបានប្រសើរឡើង នៅគ្រប់ថ្នាក់ទាំងអស់ នៃប្រព័ន្ធសុខាភិបាល។ ចាប់តាំងពីការអភិវឌ្ឍន៍នូវប្រព័ន្ធព័ត៌មានសុខាភិបាលនាឆ្នាំ ១៩៩៣ មក ការទាមទារនូវព័ត៌មានសុខាភិបាលមានការកើនឡើងយ៉ាងឆាប់រហ័ស។ ទាំងនេះគឺបណ្តាលមកពីការពង្រីកនៃសេវាសុខាភិបាល និង កម្មវិធីទប់ស្កាត់ និង ការពារជំងឺឆ្លង នៅទូទាំងប្រទេស ការលេចចេញ នូវបញ្ហាសុខភាពសាធារណៈថ្មីៗ ដូចជាជំងឺ សារ (SARS) និងជំងឺគ្រុនផ្តាសាយបក្សី ហើយនិងតំរូវការពីម្ចាស់ជំនួយនានាអំពីព័ត៌មាន សំរាប់ត្រួតពិនិត្យតាមដានគំរោងរបស់គេ។ ជាបច្ច័យការទាមទារនូវព័ត៌មាននេះបានបង្កើតជាបន្ទុកដ៏ធ្ងន់ធ្ងរធ្លាក់ទៅ លើមន្ត្រីទទួលបន្ទុកព័ត៌មានសុខាភិបាល នៅគ្រប់ថ្នាក់ទាំងអស់នៃប្រព័ន្ធសុខាភិបាល នូវការផលិតទិន្នន័យមានគុណភាពខ្ពស់ ទាន់ពេលវេលា និងពាក់ព័ន្ធ។

**វិស័យនានា និងដៃគូ** (multiple sectors and stakeholders): ទស្សនាទាននៃ ប្រ.ព.ស មិនមែនសំដៅតែ វិស័យសុខាភិបាលមួយប៉ុណ្ណោះទេ ដោយហេតុថាស្ថិតិសុខាភិបាលត្រូវបានផលិត និង ប្រើប្រាស់ដោយស្ថាប័ន និង អង្គការនានាជាច្រើនទៀត។ ទាំងនេះរួមមានកម្មវិធីជាតិ ផ្នែកឯកជន ហើយនិងទីភ្នាក់ងារអភិវឌ្ឍន៍នានា។ តែទោះជាយ៉ាងណាក៏ដោយ ការខំប្រឹងប្រមូលទិន្នន័យត្រូវបានកាត់ផ្តាច់ជាកង់ៗដោយសារតែ (fragmented) ការសំរបសំរួលនៅមានកំរិតទាំងនៅក្នុង និង នៅក្រៅវិស័យសុខាភិបាល។ ជាបច្ច័យការធ្វើអង្កេតជាច្រើនអំពីសុខភាព និង ទាក់ទងទៅនិងសុខភាពត្រូវបានធ្វើឡើងនៅក្នុងពេលថ្មីៗនេះ ដោយមិនមានការធ្វើផែនការ និង សំរបសំរួលគ្នាបានសមស្របឡើយ ដើម្បីជៀសវាងការប្រមូលទិន្នន័យត្រួតគ្នា ហើយនិង គំលាតនៃពេលវេលាសមស្របរវាងអង្កេតនីមួយៗ។ ផ.យ.ប្រ.ព.ស ដែលគួរតែអាចបង្កើតជាមូលដ្ឋានសំរាប់ ការធ្វើផែនការដែលមានលក្ខណៈសំរបសំរួល និងមានសុខដុមនីយកម្ម មិនធ្លាប់ត្រូវបានអភិវឌ្ឍទេ ហេតុនេះ ការគាំទ្រផ្នែកថវិកា និងបច្ចេកទេសដែលផ្តល់ឱ្យដោយបណ្តាញរង្វាស់សុខភាព គឺជាឱកាសមួយដ៏ល្អក្នុងការជួបជុំគ្នាជាមួយដៃគូទាំងអស់ដែលពាក់ព័ន្ធ ដើម្បីចាប់ផ្តើមរៀបចំ ការធ្វើផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល។

**គុណភាពទិន្នន័យ:** គំនិតផ្តួចផ្តើមនៃភាពជាដៃគូនៅក្នុងស្ថិតិដើម្បីការអភិវឌ្ឍន៍នៅក្នុងសតវត្សទី ២១ ដែលហៅកាត់ថា PARIS 21 (Partnership in statistics for development in the 21st century)

ហើយនិងផែនការយុទ្ធសាស្ត្រស្ថិតិ ២០០២-២០០៧ នៃវិទ្យាស្ថានជាតិស្ថិតិបានបញ្ជាក់ថា នៅក្នុងប្រទេសកម្ពុជា ការខំប្រឹងប្រែងយ៉ាងទូលំទូលាយដើម្បីវាយតំលៃ និងធ្វើឱ្យប្រសើរឡើងនូវគុណភាពទិន្នន័យស្ថិតិ បានចាប់ផ្តើមហើយ។ ដូច្នេះវាបានផ្តល់ឱកាសបន្ថែមទៀត ដើម្បីពង្រឹង ប្រ.ព.ស ជាតិនៅក្នុងបរិបទនៃការខំប្រឹងប្រែងនេះ តាមរយៈការកសាង ផ.យ.ប្រ.ព.ស ដែលឈ្ពោះទៅកាន់ការបង្កើនគុណភាពខ្ពស់នៃទិន្នន័យ ដែលអាច បង្កើតជាមូលដ្ឋានសំរាប់ធ្វើការសំរេចចិត្តបានត្រឹមត្រូវ។

**បណ្តាញវង្វាស់សុខភាព** (Health Metrics Network (HMN): គឺជាភាពជាដៃគូសុខភាពសកលដែលផ្តោតលើការពង្រឹងប្រព័ន្ធស្ថិតិ និង ប្រព័ន្ធព័ត៌មានសុខាភិបាល ជាជាងផ្តោតលើតែជំងឺណាមួយ ឬកម្មវិធីដែលទាក់ទងទៅនឹងជំងឺប៉ុណ្ណោះ។ បណ្តាញវង្វាស់សុខភាព បានប្រមូលផ្តុំអ្នកផលិត និង អ្នកប្រើប្រាស់ព័ត៌មានសុខាភិបាល ក្នុងការគាំទ្រការខំប្រឹងប្រែងរបស់ប្រទេសដើម្បីពង្រឹង ប្រ.ព.ស របស់ខ្លួន (Health Metrics Network/WHO, 2006).

**បញ្ហាសុខភាពអាទិភាព:** សេវាសុខាភិបាលសារវ័ន្ត ហើយនិងអាំងឌីកាទ័រសុខភាពដែលបានកំណត់នៅក្នុងសិក្ខាសាលានាខែ ឧសភាឆ្នាំ ២០០៧ ដោយក្រុមការងារ ប្រ.ព.ស ត្រូវបានលើកឡើងនៅទីនេះដោយសារតែអាំងឌីកាទ័រទាំងនោះ តំណាងឱ្យលក្ខណៈបង្អែកចាំបាច់សំរាប់ធ្វើ ផ.យ.ប្រ.ព.ស (ឧបសម្ព័ន្ធ ២)។

**ផែនការនេះគឺមានភាពចំរុះ** និង តុល្យភាពនៃផលិតផល និង សេវា ហើយនិងការផលិត និងការបែងចែកនូវធនធាន សំរាប់នាយកដ្ឋាននានានៃក្រសួងសុខាភិបាល។ សំខាន់បំផុតនោះ ផែនការនេះមានរយៈពេលប្រាំបីឆ្នាំ ដែលនៅក្នុងនោះកម្មវិធីសកម្មភាពត្រូវបានពិនិត្យមើលឡើងវិញរាល់ឆ្នាំ នៅក្នុងបរិបទដែលក្រសួងសុខាភិបាលត្រូវស្វែងរកជំនួយបន្ថែមពីម្ចាស់ជំនួយ និង រដ្ឋាភិបាល ក៏ដូចជាធានាបាននូវធនធានដែលត្រូវដាក់ពង្រាយប្រកបដោយប្រសិទ្ធិភាព និង ប្រសិទ្ធិភាពតំលៃ។ បន្ថែមពីនេះទៀត ផែនការយុទ្ធសាស្ត្រនេះជួយសំរួល នៅក្នុងការធ្វើផែនការនៅថ្នាក់ក្រោមទៀតផង។

នៅក្នុងករណីនៃផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល យើងបានលើកយកការគ្រប់គ្រងកម្មវិធីជាយុទ្ធសាស្ត្រ ដែលនិយាយអំពីផលិតផលជាក់លាក់ (ដូចជា ទិន្នន័យអំពីមរណៈភាព ហើយនិងការគ្រប់គ្រង និង ការធ្វើឱ្យប្រសើរឡើងនូវមូលហេតុនៃការស្លាប់) ហើយនិងសេវាដែលផ្តល់ឱ្យដោយក្រសួងសុខាភិបាល (ដូចជាប្រព័ន្ធឃ្លាំមើលជំងឺឆ្លង និងព័ត៌មាននៃការឆ្លើយតប)។ ផែនការបន្ថែមនេះនិងត្រូវបានពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ នៅក្នុងបរិបទនៃកម្មវិធីការងាររយៈពេល ៨ឆ្នាំ ហើយនិងមានឥទ្ធិពលដល់ផែនការប្រតិបត្តិប្រចាំឆ្នាំ ឬ ផែនការរំកិលបីឆ្នាំ។

# ចក្ខុវិស័យ គោលបំណង គោលដៅ និង យុទ្ធសាស្ត្រ ៧

## ចក្ខុវិស័យ

" ត្រូវមានព័ត៌មានសុខាភិបាល និងព័ត៌មានដែលទាក់ទងទៅនឹងសុខាភិបាល ដែលមានលក្ខណៈពាក់ព័ន្ធ ទាន់ពេលវេលា និងមានគុណភាពខ្ពស់ សំរាប់ធ្វើគោលនយោបាយ ធ្វើការសំរេចចិត្តដោយផ្អែកទៅលើភ័ស្តុតាងជាក់ស្តែង ការអនុវត្តន៏នូវកម្មវិធី និង ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃដើម្បីចូលរួមចំណែកធ្វើឱ្យសុខភាពប្រជាជនបានល្អប្រសើរឡើង" ។

## គោលបំណង

1- ធានាបាននូវការអនុវត្តន៏ខ្ពស់នៃ ប្រ.ព.ស ជាតិ ដោយគោរពតាមស្តង់ដារអន្តរជាតិ និង ទទួលបាននូវការទទួលស្គាល់ និង ការគាំទ្រនៅក្នុងចំណោមអ្នកធ្វើគោលនយោបាយ និង សាធារណៈ ។

2- ធានាបាននូវការសំរេចចិត្តដោយផ្អែកលើភ័ស្តុតាងជាក់ស្តែង តាមរយៈការត្រួតពិនិត្យតាមដាន និងការវាយតំលៃនូវការបំពេញការងារសុខាភិបាល (performance) និងធ្វើឱ្យប្រសើរឡើងការផលិតទិន្នន័យ និងការផ្សព្វផ្សាយព័ត៌មានតាមរយៈការប្រើប្រាស់នូវការប្រាស្រ័យទាក់ទង និង បច្ចេកវិទ្យាសមស្រប ។

3- ជំរុញឱ្យមាននូវ (availability) ព័ត៌មានប្រកបដោយគុណភាពអំពីប្រជាសាស្ត្រសង្គម សេដ្ឋកិច្ច ជំងឺ មរណៈភាព និង ព័ត៌មានអំពីកត្តាប្រឈមគ្រោះថ្នាក់ និង ធ្វើឱ្យប្រសើរឡើងនូវការសំរបសំរួលនៃការធ្វើផែនការអង្កេត និងការធ្វើអង្កេត (survey planning and implementation) ។

4- ពង្រឹងគុណភាពនៃកំណត់ត្រាអ្នកជំងឺ (medical records) ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងករណី ជំងឺ និង គុណភាព ភាពលេញលេញ និងទាន់ពេលវេលានៃទិន្នន័យប្រព័ន្ធឃ្លាំមើលជំងឺដើម្បីឆ្លើយតប យ៉ាងមានប្រសិទ្ធិភាពចំពោះការរាតត្បាត និងទប់ស្កាត់នៃជំងឺ ។

5- ធានាបាននូវប្រសិទ្ធិភាព និង ប្រសិទ្ធិភាពតំលៃនៃការថែទាំសុខភាព និង ការបំពេញការងារសុខាភិបាលសាធារណៈ (public health performance) តាមរយៈការគ្របដណ្តប់នៃប្រព័ន្ធព័ត៌មានសុខាភិបាល និងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទិន្នន័យអំពីហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និង ភ័ស្តុភារ ។

# ប្រព័ន្ធព័ត៌មានសុខាភិបាលនៃប្រទេសកម្ពុជា

## សមាសភាគសំរាប់ធ្វើការអភិវឌ្ឍន៍

- គោលនយោបាយ និង ធនធាននៃ ប្រ.ព.ស
- ជំរឿន ការធ្វើអង្កេត និង ការចុះបញ្ជីអត្រានុកូលដ្ឋាន
- កំណត់ត្រាជំងឺ និង សុខភាពរួម ទាំងប្រព័ន្ធតាមដានជំងឺ
- រដ្ឋបាលសេវាសុខាភិបាល និង ប្រព័ន្ធទ្រទ្រង់
- ការគ្រប់គ្រងទិន្នន័យ ការផ្សព្វផ្សាយ និងការប្រើប្រាស់

## គោលដៅ និង យុទ្ធសាស្រ្តនៃប្រព័ន្ធព័ត៌មានសុខាភិបាល

| គោលដៅ | យុទ្ធសាស្រ្ត |
|---|---|
| **សមាសភាគ 1** | **គោលនយោបាយ និង ធនធាន** |
| 1. បង្កើនទិន្នន័យសុខាភិបាល ដែលមានភាពត្រឹមត្រូវ ទាន់ពេលវេលា និង ពេញលេញពីមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន។<br>To increase the availability of accurate and complete health data from public and private sources (facilities) | **1.1** ពិនិត្យឡើងវិញ និងពង្រឹងច្បាប់ និង បទបញ្ញត្តិដែលមានស្រាប់ និងបែបបទរដ្ឋបាលដែលទាក់ទងទៅនិងការកត់ត្រាទិន្នន័យសុខភាព ការរក្សាទុក ការបញ្ចេញទិន្នន័យ ការផ្សព្វផ្សាយ ទាំងនៅផ្នែកសាធារណៈ និង ឯកជន។<br>Review and strengthen existing **legislation, regulations** and administrative procedures related to health data recording, reporting, storage, retrieval, dissemination governing both public and private sector |
| | **1.2** ពង្រឹង និង អភិវឌ្ឍយន្តការសំរបសំរួលដើម្បីពង្រឹងច្បាប់ បទបញ្ញត្តិ និង បែបបទរដ្ឋបាលដែលទាក់ទងទៅនឹងទិន្នន័យសុខភាព<br>Strengthen and develop **coordinated mechanisms for enforcement** of legislation, regulations and administrative procedures, related to health data. |
| **2.** លើកកំពស់គុណភាពព័ត៌មានសុខាភិបាល<br>To improve the quality of health informtion | **2.1** ពង្រឹងការចុះអភិបាលប្រ.ព.ស និង ការផ្តល់ព័ត៌មានត្រឡប់ ដោយផ្តោតលើគុណភាពទិន្នន័យ និង ការបំពេញការងារ<br>Strengthen HIS **supervision and feedback** focused on data quality and performance standards adherence |
| | **2.2** ធ្វើការវាយតំលៃពិសេសអំពីមូលដ្ឋាន ប្រ.ព.ស ( ឧបករណ៏ សំភារៈ គ្រឿងសង្ហារឹម ព័ត៌មាន បច្ចេកវិទ្យា ការប្រាស្រ័យទាក់ទង ទីកន្លែង និង បុគ្គលិក) នៅគ្រប់ថ្នាក់ទាំងអស់។ Conduct **special assessments** of HIS facilities (tools, materials, furniture, ICT means, location, and staffing) at all levels |
| | **2.3** ផ្តល់ប្រាក់លាភការៈ និង ផលប្រយោជន៏ដល់មន្ត្រីបំរើការនៅក្នុងផ្នែកប្រ.ព. ស នៅគ្រប់ថ្នាក់ទាំងអស់។<br>Provide **incentives and benefits** linked to MBPI for staff involved in the HIS at all level |
| **3.** ពង្រឹងការប្តេជ្ញា ការសំរបសំរួល និង ការផ្តល់ធនធានសំរាប់ប្រព័ន្ធព័ត៌មានសុខាភិបាល។ | *កំណត់សំគាល់: លុប ៣.១ រួចបញ្ចូលគ្នាទៅក្នុង ៤.២* |
| | **3.1** ពង្រឹង និងបន្តរក្សាទុកនូវការទទួលខុសត្រូវរបស់ក្រុមដៃគូការងារ ប្រ.ព.ស ដោយចាត់ទុកជាអ្នកផ្តល់បច្ចេកទេសសំរាប់ការសំរបសំរួលអន្តរក្រសួង ចំពោះទិន្នន័យដែលទាក់ទងទៅនិងសុខាភិបាល ហើយនិងផ្សាភ្ជាប់ទៅនិងក្រុមការងារបច្ចេកទេសសុខាភិបាល ហើយនិង |

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| To enhance HIS commitment, coordination and resources. | ក្រុមប្រឹក្សាស្ថិតិ ។<br>Strengthen and maintain the continuing authority and responsibility of the HIS Stakeholders Working Group (SWG) as a technical **instrument of inter-sectoral coordination** for health related data and link to TWGH and the Statistical Advisory Council (SAC) |
| | **3.2** ដាក់បញ្ចូលយុទ្ធសាស្ត្រនៃ ប្រ.ព.ស និង ផែនការអនុវត្តន៏ទៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-១៥ ហើយនិង ផែនការប្រតិបត្តិប្រចាំឆ្នាំ ។<br>**Integrate the HIS strategy and implementation plan** into the future health strategic plan (HSP) 2008-2015 and health sector AOPs |
| | **3.3** ធ្វើឱ្យទាន់សម័យនូវសំណុំអំាងឌីកាទ័រស្នូលដែលទាក់ទងទៅនឹងសុខភាព ហើយនិងប្រភពផ្សេងៗនៃទិន្នន័យ (រួមមានមូលហេតុនៃការស្លាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន) សំរាប់ធ្វើការត្រួតពិនិត្យតាមដាន ។<br>Periodically update the **core set of health-related indicators** and the multiple sources of data (including CoD from the CR) for monitoring them. |
| | **3.4** ធានាបាននូវការផ្តល់នៃថវិកាសំរាប់ សកម្មភាពនៃប្រ.ព.ស ដោយអង្គភាពផ្តល់ថវិកា<br>Insure that Budget Management Centers include **provision for routine HIS costs** |
| **សមាសភាគ 2** | **ការគ្រប់គ្រងទិន្នន័យ ការផ្សព្វផ្សាយ និង ការប្រើប្រាស់** |
| **4.** បង្កើនការចែករំលែក ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យ ។<br>To increase data sharing, management, analysis, dissemination and use. | **4.1** បង្កើនការអភិវឌ្ឍន៍ ការប្រើប្រាស់ និង ការថែទំានូវប្រព័ន្ធព័តិមាន ការប្រាស្រ័យទាក់ទង និង បច្ចេកវិទ្យា សំរាប់ធ្វើការគ្រប់គ្រងទិន្នន័យសុខាភិបាល និង ការប្រាស្រ័យទាក់ទង (វចនានុក្រមមេតាទិន្នន័យ និង ឃ្លាំងស្តុកទិន្នន័យ និង ការប្រាស្រ័យទាក់ទងអ៊ិនត្រាណេត)<br>The **development, use, and maintenance of ICT systems** for health data management and communications (metadata dictionary and data warehouse, inter and intranet communications). |
| | **4.2** **ពង្រឹងសមត្ថភាព**មន្ត្រីបំរើការនៅក្នុងផ្នែកប្រ.ព. ស តាមរយៈការបណ្តុះបណ្តាលបន្ត និង កែរឹតសញ្ញាប័ត្រអំពីអេពីដេមីសាស្ត្រ ជីវស្ថិតិ អនុបណ្ឌិតសុខភាពសាធារណៈ ហើយនិងការអភិវឌ្ឍន៍សុសវែរ ការប្រើប្រាស់ប្រព័ន្ធព័តិមាន ការប្រាស្រ័យទាក់ទង និង បច្ចេកវិទ្យា និង ការថែទំា ។ |

| គោលដៅ | យុទ្ធសាស្រ្ត |
|---|---|
| | Strengthen the capacity of staff involved in the HIS through **in-service training and degree programs on** epidemiology/biostatistics/MPH, and software development, ICT use and maintenance. |
| | **4.3** ពង្រឹងបែបបទនៃការត្រួតពិនិត្យតាមដានរួមគ្នា (ការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ) ដើម្បីតាមមើលការអនុវត្តន៍ និង ផលប៉ះពាល់នៃផែនការយុទ្ធសាស្រ្តសុខាភិបាល ២០០៨-២០១៥។<br>Strengthen the **joint monitoring process** (Joint Annual Review: JAPR) for tracking the implementation and impact of the health sector strategic plan 2008-2015. |
| | **4.4** ការដាក់បញ្ចូលនូវអំាងឌីកាទ័រសំខាន់ៗពីកម្មវិធីជាតិនានាទៅក្នុង ប្រ.ព.ស នៅថ្នាក់ប្រតិបត្តិនានា (ម.ស.ខ និង ស្រ.ប្រ)<br>Integration of selected **indicators** from various national programs into the routine HIS at critical levels (OD, PHD) |
| | **4.5** អភិវឌ្ឍ និង ប្រើប្រាស់បែបបទនៃការវាយតំលៃនូវការបំពេញការងារ និង ការរីកចំរើនសំរាប់អ្នកគ្រប់គ្រង និង មន្រ្តីនៅថ្នាក់ខេត្ត ស្រុក ដោយធ្វើឱ្យពួកគេចូលរួមនៅក្នុងការប្រើប្រាស់ទិន្នន័យសេវាសុខាភិបាល ការតាមដាន និង រដ្ឋបាល។<br>Develop and apply a process of **service performance assessment and improvement** for teams of managers and staff at provincial, district and facility level which engages them in the use of routine service, surveillance and administrative data |
| **សមាសភាគ 3** | **ជំរឿន ការចុះបញ្ជីអត្រានុកូលដ្ឋាន និង ការធ្វើអង្កេត** |
| **5.** បង្កើនទិន្នន័យប្រជាជននិង ប្រជាសាស្រ្ត-សង្គម និង ការប្រើប្រាស់ នៅគ្រប់លំដាប់នៃ ប្រព័ន្ធសុខាភិបាល និង ថ្នាក់រដ្ឋបាលដើម្បីលើកកំពស់សុខភាព និង ការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រង នៃការផ្តល់សេវា<br>Increase the availability and use of population and socio-demographic data down to local administrative | **5.1** អភិវឌ្ឍ និង អនុវត្ត បែបបទសំរាប់បង្កើត និង ផ្តល់ទិន្នន័យជំរឿន ហើយនិងការព្យាករណ៍ប្រជាជនរហូតដល់ថ្នាក់រដ្ឋបាលក្រោមបំផុត។<br>Develop and implement **procedures** for generating and providing census data and population projections to the smallest administrative levels |
| | **5.2** ធ្វើការ**បណ្តុះបណ្តាល**ដល់មន្រ្តីជាន់ខ្ពស់នានា (ប្រធាន) អំពីការប្រើប្រាស់នូវទិន្នន័យជំរឿនសំរាប់ធ្វើផែនការ និង ការត្រួតពិនិត្យតាមដាន ហើយនិងមន្រ្តីជំរឿនសំខាន់ៗអំពីគ្រប់ដំណាក់កាលទំាងអស់នៃការគ្រប់គ្រងជំរឿន។<br>Provide training for service managers on the use of census data for planning and monitoring; and for core census staff on all phases of census management. |
| | **5.3** បន្ថែមសំណួរអំពីការស្លាប់របស់មនុស្សពេញវ័យទៅក្នុងសំណួរជំរឿន ហើយនិងធ្វើអង្កេតក្រោយជំរឿនអំពីមូលហេតុនៃការស្លាប់។ Add adult mortality questions to the **census questionnaire**, and conduct a **post-census survey** on cause of death |

| **គោលដៅ** | **យុទ្ធសាស្ត្រ** |
|---|---|
| levels for improving health and service monitoring and management. | |
| **6.** ធ្វើឱ្យប្រសើរឡើងនូវការគ្របដណ្តប់ និង ការប្រើប្រាស់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមានមូល ហេតុនៃការស្លាប់នៅមូលដ្ឋាន សុខាភិបាល និង នៅក្នុងសហគមន៍។<br>Improve coverage and use of civil registration (CR) including causes of death at health facilities and community level | **6.1** ធ្វើផែនការ និងអនុវត្តនូវការពង្រីកនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន នៅមូលដ្ឋានសុខាភិបាល ហើយនិងនៅក្នុងសហគមន៍ រួមមានការបណ្តុះបណ្តាល និង ការបោះពុម្ពផ្សាយ ។<br>Plan and implement the expansion of **Civil Registration system** at health facilities and within communities, including training, and publishing |
| | **6.2** ដាក់បញ្ចូល និង បណ្តុះបណ្តាលអំពីចំណាត់ថ្នាក់អន្តរជាតិនៃជំងឺតាម អាយ-ស៊ី-ឌី ១០ និងអំពីការស្រាវជ្រាវមូលហេតុនៃការស្លាប់តាមការសាកសួរ ។ Introduce and train in **ICD-10** coding and **verbal autopsy**. |
| **7.** បង្កើនទិន្នន័យអង្កេត រួមមានជំងឺមិនឆ្លង និង កត្តាប្រឈមគ្រោះថ្នាក់ ។<br>Increase availability of survey data, including non-communicable diseases (NCDs) and risk factors. | **7.1** ការតាក់តែង និង រៀបចំផែនការរយៈពេលវែងដែលមានលក្ខណៈសំរបសំរួលអំពីការធ្វើអង្កេតប្រជាជន ដោយរួមទាំងជំងឺមិនឆ្លងមួយចំនួន និង កត្តាប្រឈមគ្រោះថ្នាក់ ។<br>**Long-term coordinated planning and design of population based surveys** including priority non-communicable diseases and risk factors. |
| | **7.2** ធ្វើការបណ្តុះបណ្តាលអំពីការតាក់តែងនៃការធ្វើអង្កេតគ្រួសារ ការគ្រប់គ្រងទិន្នន័យ និង ការធ្វើវិភាគ ។<br>Conduct **training on household survey** design, processing and analysis |
| **សមាសភាគ 4** | **កំណត់ត្រាជំងឺ និង សុខភាពរួមទាំងប្រព័ន្ធតាមដានជំងឺ** |
| **8.** ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកត់ត្រាអ្នកជំងឺ ការរក្សាទុកដាក់ និងប្រព័ន្ធបញ្ចេញទិន្នន័យ នៅមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន ។ | **8.1** ពិនិត្យកែសំរួលឡើងវិញ និង ពង្រឹងការគ្រប់គ្រងកំណត់ត្រាអ្នកជំងឺ ( កំណត់ត្រាវេជ្ជសាស្ត្រ ការរក្សាទុក ហើយនិង ការបញ្ចេញទិន្នន័យ) នៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ រួមទាំងការដាក់កូដចំណាត់ថ្នាក់អន្តរជាតិនៃជំងឺ ។<br>Revise and strengthen **patient record management** (medical records, storage and retrieval facilities) in all public health facilities, including ICD coding. |
| | **8.2.** ធ្វើការ**បណ្តុះបណ្តាល** គ្រូបង្គោលសំរាប់គ្រូពេទ្យ អំពីការគ្រប់គ្រងកំណត់ត្រាអ្នកជំងឺ |

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| Improve the patient medical record, storage, and retrieval system at public and private health facilities. | Provide a **TOT training course** for clinicians in patient record management |
| **9.** ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដានជំងឺ ការធ្វើរោគវិនិច្ឆ័យ ការរាយការណ៍បន្ទាន់នៃករណីជំងឺ និង ការឆ្លើយតបទាន់ពេលវេលាទៅនឹងការរាតត្បាតនៃជំងឺ ។<br>Improve the national disease surveillance system, diagnosis, case notification and timely outbreak response. | **9.1** ពង្រឹងប្រព័ន្ធតាមដានជំងឺ និង ដំណើរការ រួមមានការធ្វើឱ្យទាន់សម័យនូវបញ្ជីជំងឺដែលត្រូវរាយការណ៍បន្ទាន់ និយមន័យករណីជំងឺ ការរាយការណ៍បន្ទាន់ ការបញ្ជាក់ពីមន្ទីរពិសោធន៍ និង ការឆ្លើយតបទៅនិង ការរាតត្បាតនៃជំងឺ ការគូសផែនទីប្រជាជនប្រឈម និងគ្រោះថ្នាក់ និង ការចែករំលែក ទិន្នន័យ និង ការផ្សព្វផ្សាយ ។<br>**Strengthen the disease surveillance system and procedures**, including updating the list of notifiable diseases, their case definitions, notification, lab confirmation and response procedures, mapping of at-risk populations and data sharing and publication. |
| | **9.2** ធ្វើការ**បណ្តុះបណ្តាល**អំពីការធ្វើរោគវិនិច្ឆ័យគ្លីនីក និងមន្ទីរពិសោធន៍ ការវិភាគទិន្នន័យ ដំណើរការនៃការឆ្លើយតបទៅនិង ការរាតត្បាតនៃជំងឺ Training – clinical and lab diagnosis, data analysis, response procedures. |
| **10.** ពង្រឹងការរាយការណ៍ករណីជំងឺ ការត្រួតពិនិត្យតាមដាន និងការឆ្លើយតបទៅនិងជំងឺមិនឆ្លង ។<br>Strengthen the case reporting, monitoring and response to NCDs. | **10.1** អភិវឌ្ឍការរាយការណ៍អំពីជំងឺមិនឆ្លង នៅក្នុងប្រព័ន្ធតាមដានជំងឺរួម និងប្រព័ន្ធឆ្លើយតប ដោយរួមបញ្ចូលគ្រោះថ្នាក់ចរាចរ និង របួស<br>Develop the **reporting of non-communicable diseases** in the overall surveillance and case reporting and response system, including accidents and injuries |
| **សមាសភាគ 5** | **រដ្ឋបាលសេវាសុខភិបាល និង ប្រព័ន្ធទ្រទ្រង់** |
| **11.** ពង្រីកការចូលរួមរបស់វិសយ័ឯកជន នៅ ក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលជាតិ ។<br>To expand the participation in the national HIS by the private sector. | **11.1** ពង្រីកការចូលរួមរបស់អ្នកផ្តល់សេវាឯកជនទៅក្នុង ប្រ.ព.ស ជាតិ រួមមានប្រព័ន្ធតាមដានជំងឺ តាមរយៈការធ្វើបញ្ជីសាពើរភ័ណ្ឌនៃអ្នកផ្តល់សេវាទាំងនោះ ធ្វើឱ្យគេយល់ដឹង និង ផ្តល់ព័ត៌មានដល់ពួកគេអំពីច្បាប់ ហើយនិងផ្តល់នូវគំរូរបាយការណ៍ស្តង់ដារ និងសំរបទៅតាមប្រព័ន្ធសុសវែរនៃ ប្រ.ព.ស ។<br>**Broaden the participation of private providers** in the national HIS, including the surveillance system, through inventorying them, and sensitizing and informing them about legislation, and providing them with the necessary |

| គោលដៅ | យុទ្ធសាស្ត្រ |
| --- | --- |
| | standard forms, and adjusting HMIS software. |
